អង្គការសាលារៀនទន្សាយ

របាយការណ៍ប្រចាំឆ្នាំ ២០២៤

អាសយដ្ឋាន៖ ស្ថិតក្នុងសាលាបឋមសិក្សាទួលគោក វិថី២៨៩ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទទំនាក់ទំនង៖ ០១២៣៦៩៣៧៦

អ៊ីម៉ែល៖ huntouch40@gmail.com

គេហទំព័រ៖ www.rabbitschoolcambodia.net.

មាតិកា

ពាក្យកាត់ 3

1. របាយការណ៍ហិរញ្ញវត្ថុ ប្រចាំឆ្នាំ ២០២៤ 4

2. របាយការណ៍សវនកម្ម 4

3. បញ្ហាប្រឈម យុទ្ធសាស្ត្រ និងផែនការបន្តាប់ 10

4. និរន្តរភាព 10

5. សកម្មភាពពិនិត្យតាមដាន និងវាយតម្លៃ 11

6. ការទំនាក់ទំនង និងការមើលឃើញនៃគម្រោង 11

7. ករណីសិក្សា 12

ឧបសម្ព័ន្ធ៖ រូបថតសកម្មភាព 14

ពាក្យកាត់

Acronyms/Abbreviations	Full words
MoSVY	Ministry of Social Veteran and Youth Rehabilitation
MoEYS	Ministry of Education Youth and Sport
PoSVY,	Provincial of Social Veteran and Youth Rehabilitation
PoE	Provincial Office of Education
DoSVY	District of Social Veteran and Youth Rehabilitation
DoE	District Office of Education
DTMT	District Training and Monitoring Team
SSC	School Support Committee
SD	School Director
DCWC,	District Council for Woman and Children
CCWC,	Commune Council for Woman and Children
CWID	Children with Intellectual Disabilities
OOSC	Out Of School Children
PwDs	Person with Disability
YwID	Youth with Intellectual disability
NGO	Non-Government Organization
RSO	Rabbit School Organization
NISE	National Institute for Special Education
EPC	Essential Personal Cambodia
HI	Human Inclusion
DDP	Deaf Development Program
PPCIL	Phnom Penh Center for Independent Living - PPCIL
RTI	Research Triangle Institute
CRS	Catholic Relief Service
NEP	NGO Education Partnership
CAMFEBA	Cambodian Federation of Employers and Business Associations (CAMFEBA)
NEA	National Employment Agency
GMAC	Garment Manufacturers Association in Cambodia
HHC	Hand of Hope Community

1. របាយការណ៍ហិរញ្ញវត្ថុ ប្រចាំឆ្នាំ ២០២៤

លេខរៀង	ចំណាយប្រតិបត្តិការណ៍	ចំនួនទឹកប្រាក់ជាដុល្លារ
១	ធនធានមនុស្ស	១០៥.១២៥,៥១
២	ការធ្វើដំណើរ	២៩២,១៦
៣	ឧបករណ៍ និងសម្ភារៈផ្គត់ផ្គង់	១.១៤២,៥០
៤	គ្រឿងបរិក្ខារក្នុងស្រុក	៨.៤៥០,២៧
៥	ចំណាយលើសកម្មភាព	១៦៧.៧០៥,៨៥
សរុប		**២៨២.៧១៦,២៩ ដុល្លារ**

2. របាយការណ៍សង្ខេប

កម្មវិធីអប់រំរបស់សាលារៀនទន្សាយត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍ទូលំទូលាយ រួមទាំងការលូតលាស់ផ្នែកសង្គម អារម្មណ៍ ផ្លូវកាយ ផ្លូវចិត្ត និងបញ្ញារបស់កុមារដែលមានពិការភាពខាងសតិបញ្ញា និងអូទីស្សឹម ដែលធ្វើការឆ្ពោះទៅរកការធ្វើសមាហរណកម្មពេញលេញរបស់ពួកគេទៅក្នុងសង្គម។ កុមារអាចចុះឈ្មោះចូលរៀនក្នុងកម្មវិធីសាលារៀនទន្សាយចាប់ពីអាយុ ៤ ឆ្នាំ និងត្រូវបានគាំទ្ររហូតដល់អាយុ ២៥ ឆ្នាំ។

នៅដំណាក់កាលនីមួយៗនៃកម្មវិធីរបស់សាលារៀនទន្សាយ សិស្សរបស់យើងត្រូវបានវាយតម្លៃ គាំទ្រ និងអប់រំតាមរបៀបដែលត្រូវបានរៀបចំឡើងជាពិសេសដើម្បីបំពេញតម្រូវការរបស់សិស្សម្នាក់ៗ។ នៅសាលារៀនទន្សាយ កុមារម្នាក់ៗត្រូវបានលើកទឹកចិត្តឱ្យមានការអភិវឌ្ឍន៍ និងមានភាពឯករាជ្យជាងមុន ដោយគិតទៅតាមចរិតលក្ខណៈផ្ទាល់ខ្លួន និងគោលដៅរបស់ពួកគេម្នាក់ៗ។

កម្មវិធីអប់រំរបស់សាលារៀនទន្សាយរួមមាន ការអប់រំពិសេស ការអប់រំថ្នាក់សមាហរណកម្ម និងការអប់រំបរិយាបន្ន ការអប់រំមុនការបណ្តុះបណ្តាលវិជ្ជាជីវៈ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការផ្តល់ការងារ និងការសមាហរណកម្មទៅក្នុងសង្គមឡើងវិញនៅអាយុ ២៥ ឆ្នាំ។

សាលារៀនទន្សាយបានរៀបចំរបាយការណ៍ប្រចាំឆ្នាំនេះសម្រាប់រាយការណ៍ការអនុវត្តគម្រោងរយៈពេលមួយឆ្នាំ **គិតចាប់ពីថ្ងៃទី ១ ខែមករា ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២៤**។ របាយការណ៍នេះត្រូវបានធ្វើឡើងដោយផ្អែកលើលទ្ធផល ធាតុចេញ និងសកម្មភាព។

លទ្ធផលទី ១៖ កុមារក្រៅសាលាបានទទួលឱកាសចូលរៀនកម្រិតបឋមប្រសើរឡើងប្រកបដោយសមធម៌។

ការជុំសជុំលថ្នាក់អប់រំបរិយាប័ន្ន រួមមានបង្គន់ ជម្រាល និងបន្ទប់ថ្នាក់បរិយាប័ន្នក្នុងសាលាគោលដៅ

នៅក្នុងឆ្នាំ ២០២៤ សាលារៀនទន្សាយបានសាងសង់ជម្រាលចំនួន ២០ ដើម្បីសម្រួលការចេញចូលបង្គន់ចំនួន ១៣ បន្ទប់ ថ្នាក់សមាហរណកម្មចំនួន ៦ និងកន្លែងក្មេងលេងសម្រាប់សិស្សពិការចំនួន ១ នៅតាមសាលាគោលដៅ រួមមាន រាជធានីភ្នំពេញ អង្គស្នួល កណ្តាលស្ទឹង សំរោងទង និងស្រុកពួក។

ដំណើរការថ្នាក់សមាហរណកម្មសម្រាប់កុមារមានពិការភាពសតិបញ្ញា

គម្រោងនេះបានបន្តធ្វើការ និងគាំទ្រដល់សាលាគោលដៅទាំង ១៦ ដើម្បីថែទាំ និងដំឡើងឧបករណ៍ថ្មី ដើម្បីធានាថា ថ្នាក់សមាហរណកម្មទាំង ៤៦ ត្រូវបានបំពាក់បរិក្ខារសិក្សា និងថែទាំយ៉ាងល្អសម្រាប់ការរៀនសូត្ររបស់សិស្សដែលមានពិការភាពសតិបញ្ញា និងអូទីស្សឹម។

- ថ្នាក់សមាហរណកម្មចំនួន ៤៦/៤៦ ទទួលបានសម្ភារបង្រៀន រួមមាន នៅភ្នំពេញចំនួន ១៨ ថ្នាក់ នៅអង្គស្នួល ៥ ថ្នាក់ នៅច្បារមន ៥ ថ្នាក់ និងនៅស្រុកពួក ៥ ថ្នាក់។ សម្ភារៈដែលទទួលបានរួមមាន ក្រដាសកាតុង សៀវភៅកត់ត្រា ក្រដាសA៤ពណ៌ាស និងពណ៌ា ក្តារខៀន ហ្វឺត ទឹកថ្នាំ ការ បិច ខ្មៅដៃ ជ័រលុប បន្ទាត់ កន្ត្រែ អំបោស សាប៊ូ ចង់ផ្លាស្ទិច កន្សែងដៃ ក្រណាត់ជូតជើង បង់ស្អិត ប្រដាប់ប្រដាក្មេងលេង ។ល។
- ថ្នាក់សមហរណកម្ម ៤៦/៤៦ ក្នុងសាលាគោលដៅទាំងអស់បានទទួលគ្រឿងសង្ហារឹម និងសម្ភារៈបង្រៀន រួមមានកៅអី តុ ក្តារខៀន និងកង្ហារ។
- ថ្នាក់បរិយាបន្នចំនួន ៥៣/៥៣ ទទួលបានសម្ភារបង្រៀន រួមមាន អង្គស្នួលចំនួន ១៦ ថ្នាក់ នៅកណ្តាលស្ទឹង ៧ ថ្នាក់ នៅសំរោងទង ៩ ថ្នាក់ នៅច្បារមន ៨ ថ្នាក់ និងនៅស្រុកពួក ៤ ថ្នាក់។ សម្ភារៈដែលទទួលបានរួមមាន ក្រដាសកាតុង សៀវភៅកត់ត្រា ក្រដាសA៤ពណ៌ាស និងពណ៌ា ក្តារខៀន ហ្វឺត ទឹកថ្នាំ ការ បិច ខ្មៅដៃ ជ័រលុប បន្ទាត់ កន្ត្រែ អំបោស សាប៊ូ ចង់ផ្លាស្ទិច កន្សែងដៃ ក្រណាត់ជូតជើង បង់ស្អិត ប្រដាប់ប្រដាក្មេងលេង ។ល។

ការផ្តល់អាហារូបករណ៍ដល់កុមារក្រៅសាលា

កុមារមានពិការភាពចំនួន ២៦ នាក់ (ស្រី៖ ១០) បានចុះឈ្មោះចូលរៀននៅក្នុងឆ្នាំ ២០២៤។

ចំនួនសរុបនៃកុមារក្រៅសាលា រួមទាំងកុមារពិការ (គិតតែសម្រាប់ដំណាក់កាលទី ២ ប៉ុណ្ណោះ) មានចំនួន ២៦២៤ (ស្រី៖ ១២៦៦) បានទទួលការគាំទ្រ ក្នុងនោះរាប់ទាំងកុមារបានចុះឈ្មោះចូលរៀនថ្មី ២៦ នាក់ (ស្រី៖ ១០) កុមារនៅរៀនថ្នាក់ដដែល ២០២ នាក់ (ស្រី៖ ៦៩) កុមារបានឡើងថ្នាក់ ២៣៩៦ នាក់ (ស្រី៖ ១១៨៧)។ កុមារបោះបង់ការសិក្សាមានចំនួន ៩៦ នាក់ (ស្រី៖ ៤៤) និងបិទករណី (សិស្សចូលអនុវិទ្យាល័យ) មានចំនួន ២៤១ នាក់ (ស្រី៖ ១២៨)។

- សិស្សមានពិការភាពចំនួន ៦៣ នាក់ (ស្រី៖ ៣១) បានទទួលការឧបត្ថម្ភ ដូចជា សម្លៀកបំពាក់ សៀវភៅ និងកាបូប។
- សិស្សគ្មានពិការភាពចំនួន ២៥៨ នាក់ (ស្រី៖ ១៣៦) បានទទួលជំនួយឧបត្ថម្ភ ដូចជា សម្លៀកបំពាក់ សៀវភៅ និងកាបូប។

ការគាំទ្រគ្រួសារកុមារក្រៅសាលាលើមុខរបរ សម្ភារ និងសេវា

យុវជនមានពិការភាពសតិបញ្ញា និងអូទីស្សឹមចំនួន ២៧ នាក់ (ស្ត្រី៖ ៧) បានចូលរៀនវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនៅសាលាបឋមសិក្សាទួលគោក។ ក្នុងនោះ ៣នាក់ បានបោះបង់ការសិក្សា ដោយសារបញ្ហាគ្រួសារ និងសុខភាព។ ថង់ក្រដាសចំនួន ៣០០០ ត្រូវបានផលិត និងផ្គត់ផ្គង់ដល់អតិថិជនរបស់យើង ហើយ ១០០០ ថង់ត្រូវបានផ្គត់ផ្គង់ទៅឱ្យក្រុមហ៊ុន Bodia Nature ជារៀងរាល់ខែ។ នៅសាលារៀន ពួកគេចូលចិត្តទាំងការហ្វឹកហាត់ជំនាញទន់ និងជំនាញរឹង យូហ្គា និងសកម្មភាពកីឡា។

បុគ្គលិកគម្រោងបានបន្តតាមដានការគាំទ្រជាមួយកុមារចំនួន ៥ គ្រួសារដែលមានសកម្មភាពរបរចិញ្ចឹមជីវិត និងបង្កើតប្រាក់ចំណូល ដូចជា បោកអ៊ុត ការចិញ្ចឹមមាន់ និងហាងកាហ្វេចំនួន ១ នៅរាជធានីភ្នំពេញ និង ៤ នៅខេត្តសៀមរាប។ លើសពីនេះទៀត គម្រោងនេះបានតាមដាន និងគាំទ្រដល់យុវជនចំនួន ២ នាក់ ដែលមានពិការភាពសតិបញ្ញា និងអូទីស្សឹមនៅកន្លែងធ្វើការរបស់ពួកគេ។

លទ្ធផលទី ២៖ កុមារក្រៅសាលាបានទទួលការអប់រំកម្រិតបឋមប្រកបដោយគុណភាពនិងភាពប្រសើរឡើង

ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការអប់រំពិសេសសម្រាប់គ្រូបង្រៀនកុមារមានពិការភាពសតិបញ្ញា នាយកសាលា និងក្រុមការងារគ្រប់គ្រងបច្ចេកទេសកម្រិតស្រុក

នៅក្នុងឆ្នាំ ២០២៤ គ្រូបង្រៀនចំនួន ៣៦ នាក់ (ស្ត្រី៖ ២៤) ត្រូវបានបណ្តុះបណ្តាលក្នុងការដោះស្រាយបញ្ហាអាកប្បកិរិយាដោយមានការឧបត្ថម្ភថវិកា និងជំនួយបច្ចេកទេសពីអង្គការ Disability Support International (DSI)។ វគ្គបណ្តុះបណ្តាលនេះ ធ្វើឡើងនៅថ្ងៃទី១២-១៣ ខែមីនា ឆ្នាំ២០២៤ នៅវិទ្យាស្ថានជាតិអប់រំពិសេស (NISE) រាជធានីភ្នំពេញ។

គ្រូបង្រៀន ២០ នាក់ (ស្ត្រី៖ ១៦) ត្រូវបានបណ្តុះបណ្តាលក្នុងការព្យាបាលការនិយាយ និងភាសា ដោយមានការគាំទ្រផ្នែកថវិកាពី CIMB ។ វគ្គបណ្តុះបណ្តាលនេះធ្វើឡើងនៅចន្លោះខែវិច្ឆិកា ឆ្នាំ២០២៣ ដល់ខែមីនា ឆ្នាំ២០២៤ នៅសាលាបឋមសិក្សាទួលគោក រាជធានីភ្នំពេញ។

គ្រូបង្រៀនចំនួន ៦ នាក់ (ស្ត្រី៖ ៤) ត្រូវបានបណ្តុះបណ្តាលអំពីរបៀបជួយឪពុកម្តាយរបស់កុមារដែលមានពិការភាពសតិបញ្ញា និងអូទីស្សឹម។ វគ្គបណ្តុះបណ្តាលនេះធ្វើឡើងដោយអង្គការ Don'Yogee នៅថ្ងៃទី ១២-១៤ ខែមិថុនា ឆ្នាំ ២០២៤ នៅមជ្ឈមណ្ឌលផ្លូវចិត្តកុមារ CCAMH ក្នុងក្រុងតាខ្មៅ ខេត្តកណ្តាល។

គ្រូបង្រៀន និងបុគ្គលិកចំនួន ២០ នាក់ (ស្ត្រី៖ ១៥) ត្រូវបានបណ្តុះបណ្តាលក្នុងការប្រើប្រាស់ឧបករណ៍ ICT តាមអ៊ីនធឺណិត និងការបង្រៀនតាមអ៊ីនធឺណិត ដោយមានការគាំទ្រផ្នែកថវិកាពី World Trust ។ វគ្គបណ្តុះបណ្តាលនេះ ធ្វើឡើងនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤ នៅសាលាបឋមសិក្សាទួលគោក រាជធានីភ្នំពេញ។

វគ្គបណ្តុះបណ្តាលចំនួន ៣ វគ្គ ត្រូវបានធ្វើឡើងសម្រាប់គ្រូបង្រៀនអប់រំពិសេសចំនួន ៨៥ នាក់ (ស្ត្រី៖ ៦១) ស្តីពីការប្រាស្រ័យទាក់ទងជាមួយសិស្សដែលមានពិការភាពសតិបញ្ញា និងអូទីស្សឹម។ វគ្គបណ្តុះបណ្តាលនេះធ្វើឡើងនៅវិទ្យាស្ថានជាតិអប់រំពិសេស មន្ទីរអប់រំ យុវជន និងកីឡា កំពង់ស្ពឺ និងសាលាបឋមសិក្សាក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល។ អ្នកចូលរួមយល់អំពីប្រភេទផ្សេងៗគ្នានៃកុមារដែលមានការលំបាកក្នុងការប្រាស្រ័យទាក់ទង ដូចជា កុមារមិនអាចនិយាយជាពាក្យ និយាយពីរបីពាក្យ និយាយមិនអាចយល់បាន (ពិបាកយល់) និងការលំបាកក្នុងការយល់ដឹងសង្គម។ អ្នកចូលរួមទាំងអស់កាន់តែមានទំនុកចិត្តក្នុងការអនុវត្តយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងជាមួយសិស្សដែលមានតម្រូវការពិសេសតាមវិធីផ្សេងៗគ្នាចំពោះតម្រូវការរបស់សិស្សម្នាក់ៗ។

- វគ្គបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំពិសេស ថ្ងៃទី ២២-២៣ ខែតុលា ឆ្នាំ ២០២៤ មានគ្រូសរុបចំនួន ២៣ នាក់ (ស្រី៖ ១៥) បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ។
- វគ្គបណ្តុះបណ្តាលនៅមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ស្ពឺ ថ្ងៃទី ៧-៩ ខែវិច្ឆិកា ឆ្នាំ ២០២៤ មានគ្រូសរុបចំនួន ៣៧ នាក់ (ស្រី៖ ២៩) បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ។
- វគ្គបណ្តុះបណ្តាលនៅសាលាបឋមសិក្សាក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល នៅថ្ងៃទី ២៦-២៧ ខែធ្នូ ឆ្នាំ ២០២៤ មានគ្រូសរុបចំនួន ២៥ (ស្រី៖ ១៧) បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ។

បន្ទាប់ពីវគ្គបណ្តុះបណ្តាលនេះ មានការបង្វឹកផ្ទាល់មួយលើកជាមួយគ្រូពិសេសចំនួន ១៦ នាក់ (ស្ត្រី៖១៦) នៅរាជធានីភ្នំពេញ។

ការគាំទ្រចំណេះដឹង ICT ដល់គ្រូបង្រៀនអប់រំពិសេស៖ សាលារៀនទន្សាយបានបញ្ជូនគ្រូពិសេសចំនួន ១៦ នាក់ (ស្ត្រី៖ ១២) ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលរយៈពេល ៣ ខែ វគ្គមូលដ្ឋានគ្រឹះកុំព្យូទ័រ និង Microsoft office។

ការរៀបចំកិច្ចប្រជុំគាំទ្របច្ចេកទេសគ្រូដើម្បីផ្តល់ការគាំទ្រដល់ថ្នាក់សមាហរណកម្មនិងអប់រំបរិយាប័ន្ននៅសាលាគោលដៅ

កិច្ចប្រជុំបច្ចេកទេសចំនួន ២០ លើក បានធ្វើឡើងនៅក្នុងសាលាគោលដៅដែលក្នុងនោះ ១១ លើកនៅរាជធានីភ្នំពេញ ៣ លើកនៅស្រុកអង្គស្នួល ១ លើកនៅស្រុកកណ្តាលស្ទឹង ២ លើកនៅក្រុងច្បារមន និង ៣ លើកទៀតនៅសៀមរាប។ គ្រូបង្រៀនពិសេសចំនួន ២៩៧ នាក់ (ស្ត្រី៖ ២០០) និងគ្រូបង្រៀនបរិយាបន្នបានចូលរួមក្នុងកិច្ចប្រជុំបច្ចេកទេសទាំងនេះ។ ប្រធានបទសម្រាប់កិច្ចប្រជុំបណ្តុះបណ្តាលបច្ចេកទេសរួមមាន បញ្ហាអាកប្បកិរិយា ពេលវេលាធ្វើការ និងគោលនយោបាយបុគ្គលិក ការអភិវឌ្ឍន៍ផែនការអប់រំសិស្ស ការថែទាំសុខភាព និងការថែទាំខ្លួនឯងនៅកន្លែងធ្វើការ ចិត្តសាស្ត្រសម្រាប់កុមារអូទីស្សឹម បញ្ហាអាកប្បកិរិយា និងការប្រាស្រ័យទាក់ទងជាមួយកុមារមានតម្រូវការពិសេស។

ការរៀបចំទស្សនៈកិច្ចត្រួតពិនិត្យ និងតាមដានសកម្មភាពការងារនៅក្នុងតំបន់គោលដៅ

ការចុះត្រួតពិនិត្យការងារចំនួន ៣ លើក ត្រូវបានធ្វើឡើងនៅចន្លោះខែមករា ដល់ខែមិថុនា ឆ្នាំ ២០២៤ ដោយមន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ និងអ្នកគ្រប់គ្រងគម្រោងនៅស្រុកពួក ក្រុងច្បារមន ស្រុកអង្គស្នួល និងស្រុកកណ្តាលស្ទឹង។ ក្នុងនោះមនុស្សចំនួន ៤១ នាក់ (ស្ត្រី៖ ១៣) ត្រូវបានជួបក្នុងអំឡុងពេលទស្សនកិច្ច រួមមាន មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡា នាយកសាលា គ្រូបង្រៀន ឪពុកម្តាយកុមារ និងបុគ្គលិកសាលារៀនទន្សាយ។

កិច្ចប្រជុំឆ្លុះបញ្ចាំងចំនួន ៣ លើក ត្រូវបានធ្វើឡើងនៅចន្លោះខែកក្កដា ដល់ខែធ្នូ ឆ្នាំ២០២៤ កិច្ចប្រជុំនេះបានធ្វើឡើងនៅស្រុកពួកចំនួន ១ លើក នៅក្រុងច្បារមនចំនួន ១ លើក និងនៅស្រុកអង្គស្នួលចំនួន ១ លើក។ ជាសរុប មានអ្នកចូលរួមចំនួន ៣៨ នាក់ (ស្ត្រី៖៧) មកពីបុគ្គលិកមន្ទីរ/ការិយាល័យអប់រំ យុវជន និងកីឡា នាយកសាលា និងសាលារៀនទន្សាយ។ គោលបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីពិនិត្យមើលការអនុវត្តគម្រោងគាំទ្រកុមារក្រៅសាលា បញ្ហាប្រឈម ដំណោះស្រាយ និងការផ្តល់យោបល់សម្រាប់ផែនការឆ្នាំ ២០២៥។ បញ្ហាប្រឈមដែលសាលាគោលដៅជួបប្រទះ៖ ជំនាញបង្រៀនរបស់គ្រូនៅមានកម្រិត ឪពុកម្តាយមួយចំនួនមិនអាចគាំទ្រកូនរបស់ពួកគេឱ្យចូលរៀនបានដោយសារភាពក្រីក្ររបស់ពួកគេ ចម្ងាយឆ្ងាយពីសាលារៀន សហគមន៍នៅតែមិនផ្តល់អាទិភាពដល់ពិការភាព សិស្សខ្លះគ្មានពិការភាពមិនបានលេងជាមួយសិស្សពិការ សិស្សមកពីគ្រួសារក្រីក្រគ្មានលុយទិញសៀវភៅឧបត្ថម្ភសិស្ស។ល។ សាលាគោលដៅត្រូវការជំនួយបន្ថែមក្នុង ២០២៥ ដូចជា ត្រូវការការគាំទ្របន្ថែមសម្រាប់ថ្នាក់សមាហរណកម្មដែលមានស្រាប់ ពង្រឹងការអប់រំបរិយាបន្ន កែលម្អបង្គន់ និងថ្នាក់រៀន សម្ភារៈសិក្សាសម្រាប់សិស្សក្រៅសាលា ការដឹកជញ្ជូនសម្រាប់សិស្សក្រៅសាលា ជាដើម។

វេទិកាថ្នាក់ក្រោមជាតិមួយត្រូវបានធ្វើឡើងនៅថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ២០០២៤ នៅសាលប្រជុំមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ស្ពឺ។ ក្នុងនោះមានមនុស្ស ៣៤ នាក់ (ស្ត្រី៖ ៨) បានចូលរួមក្នុងវេទិកានេះ រួមមាន មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ ១ នាក់ មន្ត្រីចុះសហគមន៍ ២ នាក់ គ្រូពិសេស ១ នាក់ ឪពុកម្តាយសិស្ស ៤ នាក់ ក្រុមប្រឹក្សាឃុំ/សង្កាត់ ៤ នាក់ នាយកសាលា ១៦ នាក់ មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡា ២ នាក់ មន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១ នាក់ ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ២ នាក់។

លទ្ធផលទី ៣៖ សមត្ថកិច្ច និងសិទ្ធិកុមារក្រៅសាលា បានពង្រឹងការទទួលខុសត្រូវគ្នាទៅវិញទៅមក។

ការធ្វើយុទ្ធនាការតាមសាលារៀនដើម្បីចុះឈ្មោះកុមារក្រៅសាលាក្នុងតំបន់គោលដៅ

ក្នុងឆ្នាំ២០២៤ យុទ្ធនាការសាលាចំនួន២បានធ្វើឡើង (១ លើក នៅស្រុកអង្គស្នួល និង១លើកទៀតនៅស្រុកកណ្តាលស្ទឹង)។ ក្នុងនោះមានអ្នកចូលរួមចំនួន ១៣៦ នាក់ (ស្ត្រី៖ ៥៧) រួមទាំងគ្រូបង្រៀន នាយកសាលា សិស្ស និងមេភូមិបានចូលរួមក្នុងយុទ្ធនាការសាលាទាំងនេះ។ គោលបំណងនៃយុទ្ធនាការរបស់សាលាគឺដើម្បីផ្ញើសារទៅកាន់ប្រជាជនទាំងអស់ដែលរស់នៅក្នុងសហគមន៍បានដឹងពីកុមារដែលបានចុះឈ្មោះចូលរៀន។ ព្រឹត្តិការណ៍នេះ យើងនិយាយអំពីកុមារមានពិការភាព កុមារលើសអាយុ កុមារចំណាកស្រុក កុមារបោះបង់ការសិក្សា និងកុមារងាយរងគ្រោះគ្រប់ប្រភេទដែលមិនទាន់បានមកសាលារៀននៅឡើយ។ យើងត្រូវគាំទ្រពួកគេដោយផ្អែកលើសិទ្ធិកុមារជាមូលដ្ឋាន។

ការរៀបចំទិវាជាតិ និងអន្តរជាតិនានាស្តីពីពីការភាព

ក្នុងឆ្នាំ២០២៤ ទិវាអូទីស្សឹមចំនួន ២ លើក ត្រូវបានរៀបចំឡើងនៅក្នុងរាជធានីភ្នំពេញ និងស្រុកអង្គស្នួល។ នៅរាជធានីភ្នំពេញ៖ សាលារៀនទន្សាយបានបញ្ជូនអ្នកចូលរួមចំនួន ៣៨ នាក់ (ស្ត្រី៖២០) ចូលរួមក្នុងទិវាអូទីស្សឹម នៅថ្ងៃទី ២ ខែមេសា ឆ្នាំ ២០២៤ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ អ្នកចូលរួមក្នុងព្រឹត្តិការណ៍នេះ សរុបមានប្រមាណ ២០០ នាក់។

កម្មវិធីរត់ដោយសាយ (SAI)៖

ព្រឹត្តិការណ៍រត់មួយ ត្រូវបានធ្វើឡើងនៅរាជធានីភ្នំពេញ នៅពហុកីឡដ្ឋានជាតិអូឡាំពិក តាមរយៈការរត់ជាមួយសាយ ដែលមានឈ្មោះថា "រត់ដោយបេះដូង" នៅថ្ងៃទី ១ មិថុនា ឆ្នាំ ២០២៤។ នៅក្នុងព្រឹត្តិការណ៍នេះមានអ្នកចូលរួមប្រមាណជាង ២០០ នាក់ Running with SAI "Running by Heart"

ទិវាកុមារចំនួនពីរត្រូវបានរៀបចំឡើងនៅរាជធានីភ្នំពេញ និងស្រុកអង្គស្នួល។ **ភ្នំពេញ៖** ទិវាកុមារត្រូវបានរៀបចំឡើងនៅរាជធានីភ្នំពេញដោយមានអ្នកចូលរួមជាង ៥០០នាក់មកពីសាលាទន្សាយ និងសិស្សសាលាសាធារណៈ។ **ស្រុកអង្គស្នួល៖** ទិវាកុមារ/កុមារ ត្រូវបានប្រារព្ធឡើងដោយមានអ្នកចូលរួមចំនួន ៣០០នាក់ រួមមានលោកគ្រូ អ្នកគ្រូ សិស្សានុសិស្សដែលមាន/គ្មានពិការភាព។

ទិវាជនពិការជាតិ និងអន្តរជាតិមួយ បានរៀបចំឡើងនៅស្រុកពួក ខេត្តសៀមរាប នាថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៤។ ក្នុងកម្មវិធីនេះ មានមនុស្សចំនួន ២២១នាក់ (ស្ត្រី៖១២៧) រួមមាន សិស្សានុសិស្សដែលមាន និងគ្មានពិការភាព លោកគ្រូ អ្នកគ្រូ នាយកសាលា និងការិយាល័យអប់រំ យុវជន និងកីឡា។ ជាលទ្ធផល អ្នកចូលរួមបានបង្កើនការយល់ដឹងអំពីសិទ្ធិជនមានពិការភាព រួមទាំងសិទ្ធិទទួលបានការអប់រំដោយដើម។ កុមារពិការមានសិទ្ធិស្មើគ្នាជាមួយកុមារដទៃទៀតនៅក្នុងសហគមន៍របស់ពួកគេ។

ការរត់ពាក់កណ្តាលម៉ារ៉ាតុន ដែលរៀបចំឡើងដោយក្រុមហ៊ុន មេនូឡាយហ្វ៍ (Manulife) និងក្រសួងទេសចរណ៍ នៅថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី និងអ្នកពាក់ព័ន្ធសំខាន់ៗ។ តំណាងសាលារៀនទន្សាយចំនួន ៦ នាក់ (ស្រី៖ ៣) បានចូលរួមនៅក្នុងព្រឹត្តិការណ៍អន្តរជាតិនេះ។ ព្រឹត្តិការណ៍នេះបានបើកជាសាធារណៈដែលមានមនុស្សប្រមាណ ១០០០០នាក់ ចូលរួមក្នុងព្រឹត្តិការណ៍នេះ។

ការរៀបចំការប្រជុំជាមួយឪពុកម្តាយនៅក្នុងតំបន់គោលដៅ

ការជួបសំណេះសំណាលជាមួយមាតាបិតាចំនួន ២២លើក ត្រូវបានរៀបចំឡើង រួមមានរាជធានីភ្នំពេញចំនួន ២លើក អង្គស្នួលចំនួន ៣លើក កណ្តាលស្ទឹងចំនួន ៧លើក នៅសំរោងទងចំនួន ៣លើក និងក្រុងច្បារមនចំនួន ៣លើក និងមានឪពុកម្តាយចូលរួមចំនួន ៣៣១ (ស្ត្រី៖ ២០០)។ គោលបំណងនៃកិច្ចប្រជុំនេះគឺដើម្បីពិភាក្សា និងធ្វើបច្ចុប្បន្នភាពអំពីវឌ្ឍនភាពនៃការអប់រំរបស់កុមារ និងបង្កើនការយល់ដឹងអំពីពិការភាព និងចូលរួមគាំទ្របន្ថែមទៀត។

ការរៀបចំ និងផ្សព្វផ្សាយលើទំព័រកាសែតជាតិ និងបោះពុម្ពព្រឹត្តិបត្រ

ចាប់ពីខែមករា ដល់ ខែមិថុនា ឆ្នាំ ២០២៤ មានការរៀបចំបោះពុម្ពផ្សាយចំនួនពីរ Awareness និង The World Bicycle's Day.

ចាប់ពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ ២០២៤ អត្ថបទចំនួន ៤ ត្រូវបានបោះពុម្ព និងបង្ហោះក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គម និងកាសែតដើម្បីលើកកម្ពស់ការអប់រំពិសេសសម្រាប់កុមារដែលមានពិការភាពសតិបញ្ញា និងអូទីស្សឹម។

- https://www.thmeythmey.com/?page=detail&id=១៩២៤១៥
- https://www.thmeythmey.com/?page=detail&id=១៩០៣៥៣
- https://www.thmeythmey.com/?page=detail&id=១៩១៥១៧
- https://www.youtube.com/watch?v=LxXjeE๘vwJc

ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីអំពីច្បាប់គោលនយោបាយ និងបទបញ្ជាពាក់ព័ន្ធកុមារក្រៅសាលា និងកុមារពិការសតិបញ្ញា រួមទាំងការបណ្តុះបណ្តាលតស៊ូមតិ និងការរំលោភបំពានផ្លូវភេទក្នុងតំបន់គោលដៅ។

វេទិកាថ្នាក់ក្រោមជាតិមួយត្រូវបានធ្វើឡើងនៅសាលប្រជុំមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ស្ពឺ។ ក្នុងនោះមានមនុស្ស ចំនួន ៣៤ នាក់ (ស្ត្រី៖ ៨) បានចូលរួមក្នុងវេទិកានេះ រួមមាន មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ ១ នាក់ មន្ត្រីសហគមន៍ ២ នាក់ គ្រូបង្រៀនអប់រំពិសេស ១ នាក់ ឪពុកម្តាយ ៤ នាក់ ក្រុមប្រឹក្សាឃុំ/សង្កាត់ ៤ នាក់ នាយកសាលា ១៦ នាក់ ការិយាល័យអប់រំស្រុក ២ នាក់ មន្ទីរអប់រំខេត្ត ១ នាក់ ការិយាល័យសង្គមកិច្ច ២ នាក់ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១ នាក់។ អ្នកចូលរួមទាំងអស់យល់អំពីបណ្ណសម្គាល់ជនមានពិការភាព និងអត្ថប្រយោជន៍សម្រាប់សេវាសង្គម រួមទាំងការអប់រំផងដែរ។ មាតាបិតាសិស្សពិការនឹងទៅសាលាឃុំ ដើម្បីចុះឈ្មោះទទួលបានបណ្ណសម្គាល់ជនមានពិការភាព។

ការសហការរៀបចំវេទិកាអប់រំបរិយាប័ន្នជាមួយក្រសួងអប់រំ និងភាគីពាក់ព័ន្ធ

វេទិកាជាតិលើកទី១២ ស្តីពីការអប់រំបរិយាបន្ន ក្រោមប្រធានបទ «នវានុវត្តន៍នៃការអប់រំក្រៅប្រព័ន្ធ និងបរិយាបន្ន» ធ្វើឡើងនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ នៅសាលប្រជុំនៃមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ចាម។ វេទិកានេះប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម ណុះ ស្លេះ រដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តមបណ្ឌិត ឌី សមស៊ីដេត អគ្គលេខាធិការនៃគណកម្មាធិការជាតិសម្រាប់ការអប់រំពេញមួយជីវិត ឯកឧត្តម ឯកឧត្តម គួច គូលំអ ទីប្រឹក្សាក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ លោកជំទាវ នាង ផល្លា ទីប្រឹក្សាវិទ្យាស្ថានជាតិអប់រំពិសេស និងមន្ត្រីជាន់ខ្ពស់ពាក់ព័ន្ធមកពីក្រសួងអប់រំ យុវជន និងកីឡា និងអង្គការដៃគូនានា។ ក្នុងវេទិកានេះ មានអ្នកចូលរួមចំនួន ១៥៥ នាក់ (ស្ត្រី៖ ២៥) មកពីក្រសួងអប់រំ យុវជន និងកីឡា អង្គការស្ថាប័នពាក់ពន្ធនានា បានចូលរួមក្នុងវេទិកានេះ រួមមានតំណាងអង្គការយូនីសេហ្វប្រចាំកម្ពុជា មណ្ឌលអប់រំខេត្ត នាយកសាលា គ្រូបង្រៀន មាតាបិតា កុមារពិការ តំណាងដៃគូអភិវឌ្ឍន៍ និងក្រសួងពាក់ព័ន្ធនានា។ វេទិកានេះសហការរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីសមាជិក WGED (HI, DDSP, RSO, RTI, AAR Japan, FH Cambodia, CWS, PAFID, HHC, NEP, Epic Arts)។ គោលបំណងនៃវេទិកាជាតិ៖

- លើកកម្ពស់ការអប់រំក្រៅប្រព័ន្ធ និងបរិយាបន្ន តាមរយៈការសម្របសម្រួលផ្នែករូបវន្ត ការអប់រំ ការផ្សព្វផ្សាយ និងការលើកកម្ពស់គុណភាពនៃកម្មវិធីសិក្សា និងការបណ្តុះបណ្តាលទូលំទូលាយសម្រាប់អ្នកអប់រំ។
- ពង្រឹងភាពជាដៃគូ និងការអនុវត្តក្នុងការអប់រំក្រៅប្រព័ន្ធ និងបរិយាបន្ន តាមរយៈការលើកកម្ពស់កិច្ចសហប្រតិបត្តិការ ការចូលរួមរបស់សហគមន៍ និងស្វែងរកការគាំទ្រសម្រាប់ការអនុវត្តគោលនយោបាយអប់រំបរិយាបន្នសម្រាប់សិស្សមានពិការភាព។
- ច្នៃប្រឌិតក្នុងការអប់រំក្រៅប្រព័ន្ធ និងបរិយាបន្នតាមរយៈការរួមបញ្ចូលនៃបច្ចេកវិទ្យា ការបង្កើតគំរូថ្មី ដើម្បីឆ្លើយតបទៅនឹងតម្រូវការចម្រុះរបស់សិស្ស និងការស្រាវជ្រាវ និងការអភិវឌ្ឍន៍។

ការគៀគរការគាំទ្រ និងត្រួតពិនិត្យជាមួយក្រសួងអប់រំយុវជននិងកីឡាទាក់ទងនឹងការបង្កើនការគាំទ្រសម្រាប់សកម្មភាពនិងគម្រោងរបស់អង្គការសាលារៀនទន្សាយ

ចាប់ពីខែមករា ដល់ ខែមិថុនាឆ្នាំ ២០២៤ កិច្ចប្រជុំថ្នាក់គ្រប់គ្រងត្រូវបានធ្វើឡើងដើម្បីពិភាក្សាអំពីរបៀបជំរុញសំណើគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា សម្រាប់គ្រូបង្រៀនអប់រំពិសេសរបស់សាលារៀនទន្សាយ។ បន្ទាប់ពីកិច្ចប្រជុំរួច លិខិតផ្លូវការមួយត្រូវបានដាក់ទៅក្រសួងអប់រំ យុវជន និងកីឡា ដើម្បីស្នើសុំកិច្ចសន្យាគ្រូជាមួយរាជរដ្ឋាភិបាលកម្ពុជា។

វេទិកាថ្នាក់ក្រោមជាតិមួយបានរៀបចំឡើង ស្តីពីបណ្ណសម្គាល់ជនមានពិការភាព និងសេវាសង្គម នៅថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០២៤ នៅសាលប្រជុំមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ស្ពឺ។ ក្នុងនោះមានមនុស្ស ៣៤ នាក់ (ស្ត្រី៖ ៨) បានចូលរួមក្នុងវេទិកានេះ រួមមាន មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ ១ នាក់ មន្ត្រីសហគមន៍ ២ នាក់ គ្រូបង្រៀនអប់រំពិសេស ១ នាក់

ឪពុកម្តាយ ៤ នាក់ ក្រុមប្រឹក្សាឃុំ/សង្កាត់ ៤ នាក់ នាយកសាលា ១៦ នាក់ ការិយាល័យអប់រំស្រុក ២ នាក់ មន្ទីរអប់រំខេត្ត ១ នាក់ ការិយាល័យសង្គមកិច្ច ២ នាក់ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១ នាក់។

ការចែករំលែកឯកសារ ឬកិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវលើបញ្ហាកុមារក្រៅសាលា

Aide et Action, Rabbit School Partnership to Help Students with Special need

3. បញ្ហាប្រឈម យុទ្ធសាស្ត្រ និងផែនការបន្ទាប់

បញ្ហាប្រឈម

- ការយល់ដឹងអំពីប្រភេទកុមារពិការរបស់សហគមន៍នៅមានកម្រិត និងការខ្វះផែនការអភិវឌ្ឍន៍បរិយាបន្នសម្រាប់សាលារៀនទាំងមូល។
- ធនធានសាលារៀននៅមានកម្រិត ដូចជា គ្រូបង្រៀនជំនាញ អាហារូបករណ៍ សម្ភារៈសិក្សា និងលទ្ធភាពប្រើប្រាស់ដើម្បីទាក់ទាញកុមារពិការឱ្យមកសាលារៀន។
- គ្រួសារកុមារធ្វើចំណាកស្រុក និងប្រាក់ចំណូលទាប។
- ធនធានមានកម្រិតនៃកម្មវិធីសិក្សា និងគ្រូជំនាញ ដើម្បីធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់យុវជនដែលមានពិការភាពសតិបញ្ញា។
- មាតាបិតានៃយុវជនមានបញ្ហាពិការភាពសតិបញ្ញាមិនមានទំនុកចិត្តលើអាជីពការងារនាពេលអនាគតសម្រាប់កូនៗរបស់ពួកគេ។ ឪពុកម្តាយចង់ទុកកូននៅផ្ទះជាជាងចូលរៀនថ្នាក់វិជ្ជាជីវៈ។
- និយោជកខ្លះប្រឈមនឹងការលំបាកក្នុងការប្រាស្រ័យទាក់ទងជាមួយនិយោជិតមានពិការភាព ដោយសារពួកគេមិនមានជំនាញប្រាស្រ័យទាក់ទងជាមួយជនពិការ។
- ថវិកានៅមានកម្រិតនៅឡើយ និងខ្វះខាតការឧបត្ថម្ភថវិកាពីម្ចាស់ជំនួយ។

យុទ្ធសាស្ត្រ និងផែនការបន្ទាប់

- ផ្តល់ប្រឹក្សាយោបល់ និងគាំទ្រសិស្សមានពិការភាពចូលរៀនតាមខេត្តនានា។
- យើងនឹងពង្រឹងសកម្មភាពលើកកម្ពស់ការយល់ដឹងសម្រាប់មាតាបិតា នាយកសាលា និងអាជ្ញាធរមូលដ្ឋានអំពីការកំណត់អត្តសញ្ញាណជនពិការ តម្រូវការសម្រាប់កុមារពិការ និងសិទ្ធិរបស់កូនរបស់ពួកគេក្នុងការទទួលបានការអប់រំស្មើៗគ្នា។
- បញ្ចុះបញ្ចូល និងតស៊ូមតិជាមួយអាជ្ញាធរមូលដ្ឋាន នាយកសាលា ការិយាល័យអប់រំ និងមន្ទីរអប់រំ ដើម្បីបង្កើនការយកចិត្តទុកដាក់លើសិទ្ធិរបស់កុមារ ជាពិសេសការអភិវឌ្ឍន៍របស់កុមារ។
- ផ្តល់ការប្រឹក្សាបន្ថែមដល់យុវជនដែលមានពិការភាពសតិបញ្ញាអំពីអត្ថប្រយោជន៍នៃជំនាញវិជ្ជាជីវៈ និងកម្មសិក្សាជំនាញ។
- ស្វែងរកមូលនិធិ និងអ្នកផ្តល់ជំនួយដើម្បីធានាការផ្តល់មូលនិធិរយៈពេលវែង។

4. និរន្តរភាព

- គ្រូបង្រៀនពិសេសទាំងអស់នៅក្នុងសាលារៀនទន្សាយ ត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា ហើយបានបញ្ចូលក្នុងគ្រូបង្រៀនជាប់កិច្ចសន្យា ហើយទទួលបានប្រាក់បៀវត្សរ៍ ៨០% ពីរាជរដ្ឋាភិបាលកម្ពុជា លើសពីនេះ សាលារៀនទន្សាយត្រូវបានទទួលស្គាល់ដោយរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា (រួមមាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា វិទ្យាស្ថានជាតិអប់រំពិសេស ជាដើម) និងនៅថ្នាក់ក្រោមជាតិត្រូវបានទទួលស្គាល់ជាអង្គការក្នុងស្រុកប្រកបដោយវិជ្ជាជីវៈក្នុងវិស័យអប់រំពិសេស។

5. សកម្មភាពពិនិត្យតាមដាន និងវាយតម្លៃ

- សាលារៀនទន្សាយធ្វើសកម្មភាពត្រួតពិនិត្យជាប្រចាំចាប់ពីថ្នាក់លើដល់ថ្នាក់ក្រោម។ មន្ត្រីសហគមន៍ចុះតាមដានសកម្មភាពប្រចាំថ្ងៃនៅក្នុងសាលាគោលដៅនីមួយៗ។
- លោកគ្រូអ្នកគ្រូត្រូវពិនិត្យប្រចាំថ្ងៃជាមួយសិស្សអំពីសកម្មភាពប្រចាំថ្ងៃ។
- ឪពុកម្តាយតាមដានការវិវត្តរបស់កូនរៀងរាល់ ៤ ខែម្តង។
- មន្ត្រីសហគមន៍ និងមន្ត្រីត្រួតពិនិត្យវាយតម្លៃ ចុះត្រួតពិនិត្យរាល់ខែ ឬពិនិត្យក្រៅផ្លូវការតាមករណី។
- នាយកសាលារៀនទន្សាយ ប្រធានផ្នែកកម្មវិធី និង ប្រធានផ្នែកហិរញ្ញវត្ថុ ធ្វើផែនការរួម អនុវត្តទាន់ពេល និងធានាប្រសិទ្ធភាពការងារ។

6. ការទំនាក់ទំនង និងការមើលឃើញនៃគម្រោង

- ហ្វេសប៊ុក៖ https://www.facebook.com/profile.php?id=100005744774672&fref=ts
- គេហទំព័រ៖ www.rabbitschoolcambodia.net

7. ករណីសិក្សា

ករណីសិក្សាទី ១

កុមារា សេក កេតន៍ស័កបណ្ឌិត



សេក កេតន៍ស័កបណ្ឌិត ជាកុមារអូទីស្សឹម កើតនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៤ នៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប។ **សេក កេតន៍ស័កបណ្ឌិត** រស់នៅជាមួយឪពុកម្តាយ ឪពុកឈ្មោះ សេន សារី ម្តាយឈ្មោះ កិន សុជាវ៉ា ហើយអ្នកទាំងពីរជាបុគ្គលិកសុខាភិបាលនៅមន្ទីរពេទ្យបង្អែកខេត្តសៀមរាប។ **សេក កេតន៍ស័កបណ្ឌិត** មានបងប្អូន២នាក់ ម្នាក់ជាបងប្រុស និង **សេក កេតន៍ស័កបណ្ឌិត** ជាកូនពៅក្នុងគ្រួសារនេះ។ **សេក កេតន៍ស័កបណ្ឌិត** ត្រូវបានគេរកឃើញថាមានអូទីស្សឹមនៅអាយុ២ឆ្នាំ ដោយមន្ទីរពេទ្យមេត្តាករុណា ហៅ "ពេទ្យយាយដី" ជាពេទ្យឯកទេសបញ្ហាផ្លូវចិត្តនៅខេត្តបាត់ដំបង។ **សេក កេតន៍ស័កបណ្ឌិត** មានអាកប្បកិរិយាពិបាកមួយចំនួន ដូចជា ពិបាកទំប្រាស្រ័យទាក់ទងភាសា ពិបាកនិយាយ ឬស្តាប់ ពិបាកផ្តោតអារម្មណ៍ ចូលចិត្តវាយខ្លួនឯងដោយវាយដើមទ្រូងធ្ងន់ ខាំដៃ យំដោយគ្មានហេតុផល និងមានអារម្មណ៍សោកសៅបំផុតស្ទើរគ្រប់ពេលវេលា។ល។

នៅឆ្នាំ ២០១៩ **សេក កេតន៍ស័កបណ្ឌិត** បានចាប់ផ្តើមការសិក្សាឆ្នាំទី១ ក្នុងថ្នាក់សមាហរណកម្មនៅសាលាបឋមសិក្សាខ្នាតស្ថិតក្នុងភូមិខ្នាត ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប និងមានចម្ងាយប្រហែល ១៨គីឡូម៉ែត្រពីផ្ទះរបស់គេ។ ក្នុងឆ្នាំ ២០១៩ គឺជាឆ្នាំដែលជំងឺកូវីដ-១៩រាតត្បាត រីករាលដាលយ៉ាងខ្លាំង ដូច្នេះគាត់មិនអាចមកសាលារៀនបានទៀងទាត់ ហើយឪពុកម្តាយបានសម្រេចចិត្តបញ្ឈប់គាត់ពីសាលារៀន។ ទោះជាយ៉ាងណាក៏ដោយគាត់បានចុះឈ្មោះម្តងទៀតនៅឆ្នាំ ២០២២ ហើយបន្តរហូតដល់ថ្ងៃនេះ។ ដោយមានការជួយជ្រោមជ្រែងពីគ្រូពិសេស **សេក កេតន៍ស័កបណ្ឌិត** បានក្លាយជាកុមារដែលមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ ដូចជាមានប្រាស្រ័យទាក់ទងគ្នាល្អប្រសើរឡើង ទាំងការស្តាប់និងនិយាយ អាកប្បកិរិយាកាន់តែប្រសើរ ឈប់វាយខ្លួនឯង មានអារម្មណ៍ល្អ បង្កើនសមត្ថភាពអាន និងសរសេរភាសាខ្មែរបានទាំងស្រៈ និងព្យញ្ជនៈ អាចអានពាក្យ ឬ ប្រយោគយ៉ាងរលូន និងជាពិសេសសមត្ថភាពក្នុងការគណនាជាដើម នាពេលបច្ចុប្បន្ន **សេក កេតន៍ស័កបណ្ឌិត** អាចសិក្សាក្នុងថ្នាក់ចំណេះដឹងទូទៅ ហៅថា "ថ្នាក់បរិយាបន្ន" ជាមួយសិស្សមិនមានពិការភាពផ្សេងទៀត។ ទោះជាយ៉ាងនេះក្តី **សេក កេតន៍ស័កបណ្ឌិត** ស្ថិតនៅក្រោមការត្រួតពិនិត្យ និងសង្កេតយ៉ាងជិតជិតដោយគ្រូពិសេស។



ក្នុងករណីនេះឆ្លុះបញ្ចាំងឱ្យឃើញថា ថ្នាក់សមាហរណកម្ម គឺជាគំរូមួយដ៏សំខាន់បំផុតក្នុងការលើកកម្ពស់សិទ្ធិស្មើគ្នាក្នុងការអប់រំសម្រាប់កុមារដែលមានពិការភាពសតិបញ្ញា ដែលពួកគេអាចទទួលបានការអប់រំដូចគ្នានឹងកុមារមិនពិការដែរ។ រដ្ឋាភិបាលគួរតែពង្រឹងការគាំទ្របន្ថែមសម្រាប់ថ្នាក់សមាហរណកម្មនានាដែលមានស្រាប់នៅក្នុងប្រទេសកម្ពុជា ក៏ដូចជាការគាំទ្រសម្រាប់ការពង្រីកថ្នាក់សមាហរណកម្មថ្មីបន្ថែមទៀតនៅទូទាំងប្រទេស។

ឪពុករបស់ **សេក កេតន៍ស័កបណ្ឌិត** បាននិយាយថា "ខ្ញុំសូមអរគុណដល់សាលារៀនទន្សាយ និង Ade At Action សម្រាប់ការចាប់ផ្តើមរបស់ពួកគេ និងគាំទ្រកូនប្រុសរបស់ខ្ញុំ ដើម្បីទទួលបានការអប់រំដូចគ្នាទៅនឹងកុមារមិនពិការដទៃទៀត" ។

ករណីសិក្សាទី ១
កុមារី វិបុល នីត



វិបុល នីតជាកុមារី កើតនៅថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៦ **វិបុល នីត** រស់នៅជាមួយឪពុកម្តាយ មានបងប្អូន២នាក់ នៅភូមិក្រាំងធំ ឃុំតាំងក្រូច ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ **វិបុល នីត** ជាកូនស្រីពៅក្នុងគ្រួសារ។ គ្រួសារនីតជាគ្រួសារក្រីក្រ។ ឪពុកនិងម្តាយរបស់នាងជាកម្មកររោងចក្រ។ បងប្រុសរបស់នាងត្រូវបានផ្ញើឱ្យមើលគោអ្នកជិតខាង។ គ្រួសាររបស់នីតមានជីវភាពក្រីក្រ។ មុនពេលចូលរួមជាមួយគម្រោងជួយកុមារក្រៅសាលា នីតជាសិស្សដែលអវត្តមានច្រើនជាង ៩០% ក្នុងថ្នាក់។ ឥឡូវនេះនាងកំពុងសិក្សាថ្នាក់ទី ២ នៅសាលាបឋមសិក្សាទួលសុកី។

វិបុល នីត ត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងគម្រោងជួយកុមារក្រៅសាលា ក្នុងឆ្នាំ ២០២៤ ដោយសារតែនាងស្ទើរតែជិតឈប់រៀនទៅហើយ ដោយស្ទើរតែ ៩០% អវត្តមានពីថ្នាក់របស់នាង។ នាងបានទទួលអាហារូបករណ៍ពីគម្រោងសម្ភារៈសិក្សា ដូចជាកង់ ឯកសណ្ឋានសិស្ស កាបូប សៀវភៅកត់ត្រា និងអង្ករ។



មុនទទួលបានការគាំទ្រពីគម្រោង **វិបុល នីត** ជាក្មេងស្រីដែលឆាប់ខឹង ឆាប់ខឹង មិនចេះអត់ធ្មត់ និងឆាប់ខឹងសូម្បីតែរឿងតូចតាចជាមួយគ្រូ និងមិត្តភក្តិរបស់នាង។ ពេលខ្លះនាងខឹងនឹងមិត្តរួមថ្នាក់របស់នាង។ មិត្តភក្តិរបស់នាងបានតវ៉ាតបទៅនាងវិញ ដែលធ្វើឱ្យនាងខឹង។ គ្រូបានព្យាយាមដោះស្រាយបញ្ហានេះដោយលើកទឹកចិត្តពួកគេឱ្យក្លាយជាមិត្តល្អ។

វិបុល នីត សប្បាយចិត្តណាស់ដែលទទួលបានអាហារូបករណ៍ពីគម្រោង ជួយកុមារក្រៅសាលា ហើយនាងបានមកសាលាទៀងទាត់ជារៀងរាល់ថ្ងៃវិញ។ ឥឡូវនេះ **វិបុល នីត** បានកែលម្អការសិក្សារបស់នាង និងផ្លាស់ប្តូរអាកប្បកិរិយារបស់នាងទៅជាវិជ្ជមាន។ នាងមានទំនាក់ទំនងល្អជាមួយគ្រូ និងមិត្តរួមថ្នាក់របស់នាង។ នាងចូលចិត្តលេងជាមួយមិត្តរបស់នាងនៅសាលា។ លើសពីនេះទៀត **វិបុល នីត** បានជួយគ្រួសារនូវការងារផ្ទះមួយចំនួន ដូចជា ការសម្អាតផ្ទះ បោកខោអាវ ជាដើម។

វិបុល នីត បាននិយាយថា *"ខ្ញុំសូមអរគុណដល់សាលារៀនទន្សាយ Aide et Action និង TCDA ដែលបានគាំទ្រខ្ញុំ"*។ ឪពុកម្តាយរបស់នាងក៏សប្បាយចិត្តជាមួយនឹងការគាំទ្រទាំងនេះផងដែរ។ នាងបាននិយាយថា *"ខ្ញុំរំភើបចិត្តណាស់ដែលឃើញកូនស្រីរបស់ខ្ញុំមានភាពប្រសើរឡើងក្នុងការសិក្សារបស់នាង"*។







ឧបសម្ព័ន្ធ៖ រូបថតសកម្មភាព

ការជុសជុលអគារ






ការផ្តល់អាហារូបករណ៍




ការប្រជុំ និងការបណ្តុះបណ្តាលអាណាព្យាបាល




ការប្រជុំបច្ចេកទេសជាមួយគ្រូអប់រំពិសេស





ការចុះត្រួតពិនិត្យ និងវាយតម្លៃការងារ





ការបណ្តុះបណ្តាគ្រូអប់រំពិសេស





ទិវាសិទ្ធិជនពិការ




ព្រឹត្តិការណ៍រត់ម៉ារ៉ាតុងនៅសៀមរាប





វេទិកាស្តីពីការងារសម្រាប់ជនមានពិការភាព




វេទិកាជាតិស្តីពីការអប់រំបរិយាន្ត



ការបោះពុម្ពផ្សាយ



